សេចក្តីផ្តើម
២កូរិនថូស១:១-៣

សំបុត្រទី ២
របស់
សាវ័កប៉ុល ជាលំដាប់ទីក្រុងកូរិនថូស

សេចក្តីផ្តើម

សាវ័កប៉ុលបានសរសេរគម្ពីរកូរិនថូសនេះដែរ។ លោកសរសេរកំណត់គម្ពីរនេះពីទីក្រុងភីលីព។ គម្ពីរ១កូរិនថូស តែលោកសរសេរពីទីក្រុងអេភេសូរ។ នៅទីក្រុងនោះ លោកបានបំពេញកិច្ចការងារបម្រើព្រះអង្គយ៉ាងខ្លាំងក្លា និងមានឥទ្ធិពលយ៉ាងក្រៃលែង។ នៅក្នុងគម្ពីរ១កូរិនថូស១៦:៩ លោកសរសេរថា "ដ្បិតមានទ្វារយ៉ាងធំ ហើយស្រួលបានបើកចំហឱ្យខ្ញុំ ហើយក៏មានពួកឃាត់ឃាំងជាច្រើនដែរ"។ ខ្ញុំយល់ថា សាវ័កប៉ុលបានបំពេញកិច្ចការងាររបស់លោកយ៉ាងមានប្រសិទ្ធភាពជាទីបំផុត ពេលដែលលោកស្នាក់នៅទីក្រុងអេភេសូរ។ ទីក្រុងនេះ ជាទីក្រុងដែលលោកបង្ហាត់បង្រៀន

គោលទ្វិរបស់គ្រីស្ទបរិស័ទ ព្រមទាំងជាទីគាំទ្រដល់ដំណឹងល្អនៃព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ លោកបានយកទីក្រុងអេភេសូរធ្វើជាមូលដ្ឋានធំបង្អស់របស់លោក ក្នុងការផ្សាយដំណឹងល្អ និងជាកន្លែងសម្រាប់ហ្វឹកហ្វឺនដល់អ្នកដឹកនាំរបស់គ្រីស្ទបរិស័ទ។ ដូច្នេះហើយ បានជាលោកមានប្រសាសន៍ពេញដោយជំនឿថា "ដ្បិតមានទ្វារយ៉ាងធំ ហើយស្រួលបានបើកចំហឱ្យខ្ញុំ..."។

នៅពេលដែលលោកបំពេញកិច្ចការងារនៅទីក្រុងអេភេសូរ លោកមិនមានពេលគ្រប់គ្រាន់ ដើម្បីធ្វើដំណើរទៅទីក្រុងកូរិនថូស។ លោកបង្កើតក្រុមជំនុំនៅទីក្រុងកូរិនថូសដោយខ្លួនលោក។ ក្រុមជំនុំនៅទីនោះ មិនបានលូតលាស់ទៅជាក្រុមជំនុំចាស់ទុំទេ គឺនៅតែជាកូនង៉ែតរហូត។ កិរិយាប្រព្រឹត្តរបស់គេ ដូចជានៅកូនក្មេងសុទ្ធសាធ។ ពួកជំនុំនៅទីក្រុងកូរិនថូស ចង់អោយលោកសាវ័កប៉ុលធ្វើដំណើរទៅទីនោះ ពីព្រោះគេចង់បានទទួលការកក់ក្តៅពីលោក។ គេចង់អោយសាវ័កប៉ុលប្រាប់គេថា តើទៅបត់ជើងតូចត្រង់ណា បត់ជើងធំត្រង់ណា ទុកជាក់ខោអាវត្រង់ណា សម្អាតបន្ទប់ដេកដោយវិធីណា។ លុះសាវ័កប៉ុលមិនអាចធ្វើដំណើរទៅតាមការអញ្ជើញរបស់គេ គេមានការតូចចិត្តចំពោះលោក។ សាវ័កប៉ុលបានសរសេរសំបុត្រលើកទីមួយ ទៅកាន់ពួកជំនុំនៅទីក្រុងកូរិនថូស ប្រាប់ថា លោកមកជួបគេនៅពេលក្រោយទៀត។

សាវ័កប៉ុលចំណាយពេលប្រមាណជាងបីឆ្នាំ ស្នាក់នៅទីក្រុងអេភេសូរ។ ក្នុងរយៈពេលបីឆ្នាំនោះ លោកមិនបានធ្វើដំណើរទៅទីក្រុងកូរិនថូសទេ។ មូលហេតុនោះធ្វើអោយពួកជំនុំនៅទីក្រុងកូរិនថូស មិនសប្បាយចិត្តជាមួយនឹងលោក។ ដោយសារ

លោកជាប់រវល់ហឹកហឹនអ្នកជីកនាំ លោកចាត់លោកទីតុស អោយទៅជំនួសលោក។ ចំណែកលោកធីម៉ូថេ ហើយរូបលោកផ្ទាល់ បានស្នាក់នៅទីក្រុងអេភេសូរ។ ក្រោយមកទៀត សាវ័កប៉ុល និងលោកធីម៉ូថេ បានធ្វើដំណើរចេញពីទីក្រុងអេភេសូរ ទៅទីក្រុងទ្រអាស់។ លោកសង្ឃឹមថា នឹងបានជួបលោកទីតុស ដែលត្រូវនាំដំណឹងពីទីក្រុងកូរិនថូសមកអោយលោកជ្រាបផង (សូមអានគម្ពីរ២កូរិនថូស២:១២-១៣)។ លុះលោកឃើញថា លោកទីតុសមិនបានមកជួបលោកដូចការព្រៀងទុក សាវ័កប៉ុល និងលោកធីម៉ូថេបានធ្វើដំណើរឆ្ពោះទៅទីក្រុងភីលីព។ នៅទីនោះ លោកបានជួបនឹងលោកទីតុសដែលនាំដំណឹងល្អពីពួកជំនុំទីក្រុងកូរិនថូសមកជូនលោក។ លោកទទួលដំណឹងពេញចិត្តពីពួកជំនុំនៅទីក្រុងកូរិនថូស ថាគេបានធ្វើតាម និងចុះចូលដល់សេចក្តីដែលលោកបានសរសេរទៅកាន់គេ នៅក្នុងសំបុត្រលើកទីមួយ។ មិនតែប៉ុណ្ណោះគេពេញចិត្តនិងចម្លើយដែលគេបានលើកជាសំណួរសួរដល់សាវ័កប៉ុល។

នៅពេលដែលសាវ័កប៉ុល ស្នាក់នៅទីក្រុងភីលីព លោកបានសរសេរសំបុត្រលើកទីពីរ បញ្ជូនមកពួកជំនុំនៅទីក្រុងកូរិនថូស។ ពួកជំនុំនៅទីក្រុងកូរិនថូសចង់បានសាវ័កប៉ុល ដែលជាសាវ័កដ៏ធំមកសួរសុខទុក្ខដល់គេ។ ប៉ុន្តែ សាវ័កប៉ុលមិនបានធ្វើដំណើរមកជួបគេទេ។ ទោះបីលោកមិនបានធ្វើដំណើរមកជួបក៏ដោយ បញ្ហាដែលពួកជំនុំទីក្រុងកូរិនថូសមានជាមួយនឹងសាវ័កប៉ុល ត្រូវបានដោះស្រាយនៅក្នុងពេលនេះតែម្តង។ ដូច្នេះហើយ បានជាយើងឃើញសាវ័កប៉ុលបើកចំហទឹកចិត្តរបស់លោក អោយពួកជំនុំនៅទីក្រុងនោះស្គាល់លោកអោយបានច្បាស់។ បើតាមយើងធ្វើការសិក្សាស្រាវ

ជ្រាងអោយបានល្អិតល្អន់ សាវ័កប៉ុលបើកទីកចិត្តរបស់លោកផ្ទាល់ខ្លួន អោយពួកជំនុំនៅទីក្រុងកូរិនថូសអោយស្គាល់លោក ជាងសំបុត្រណាៗទាំងអស់។

គម្ពីរកូរិនថូសទី២ ដោះស្រាយពីវិបត្តិផ្ទៃក្នុង ដែលកើតមានឡើងនៅក្នុងក្រុមជំនុំ។ សំបុត្រលើកទីមួយ លោកសរសេរទៅកាន់ពួកជំនុំដើម្បីដោះស្រាយបញ្ហាខ្លះៗ ព្រមទាំងណែនាំអោយមានការកែប្រែគំនិតមារយាទរបស់ពួកអ្នកជឿ ដែលត្រូវយកមកអនុវត្តនៅក្នុងជីវិតក្នុងនាមជាគ្រីស្ទបរិស័ទ។

ឥឡូវ សូមយើងសិក្សាគម្ពីរ២កូរិនថូសដូចខាងក្រោមនេះ។

ជំពូក ១

ឌាចមនា ព្រះជាម្ចាស់ប្រទានសេចក្តីសុខសាន្ត
មកសម្រាប់ជីវិតមនុស្សលោក

នៅក្នុងខ្លឹមសារនៃជំពូក១ ពិសេសខ១ និងខ២ ជាសេចក្តីណែនាំអោយយើងស្គាល់ខ្លឹមសារនៃសេចក្តីដែលសាវ៉កប៉ុលសរសេរនៅក្នុងសំបុត្រលើកទី២។ ឯសេចក្តីដែលសេសសល់នៅក្នុងជំពូក១ លោកពន្យល់ពីសេចក្តីសុខសាន្ត ដែលព្រះជាម្ចាស់ប្រទានមកសម្រាប់ជីវិតមនុស្សគ្រប់រូប។ សាវ៉កប៉ុលចាប់ផ្តើមសំបុត្ររបស់លោក ដោយការកត់សម្គាល់ដែលមានខ្លឹមសារយ៉ាងជ្រាលជ្រៅជាទីបំផុត។

សេចក្តីណែនាំ

សំបុត្រប៉ុលខ្ញុំ ជាសាវ៉កនៃព្រះយេស៊ូវគ្រីស្ត តាមបំណងព្រះ ហឬទ័យព្រះ នឹងធីម៉ូថេ ជាពូកបងប្អូន ផ្ញើមកពួកជំនុំនៃព្រះ ដែលនៅក្រុងកូរិនថូស ព្រមទាំងពួកបរិសុទ្ធទាំងអស់ផ្នា ដែលនៅគ្រប់ក្នុងស្រុកអាខៃ (២កូរិនថូស១:១)។

សាវ័កប៉ុលបញ្ជាក់នៅក្នុង១ថា "សំបុត្រប៉ុលខ្ញុំជាសាវ័កនៃព្រះយេស៊ូវគ្រីស្ទ តាមបំណងព្រះហឫទ័យព្រះ..."។ ពាក្យថាជាសាវ័កតាមបំណងព្រះហឫទ័យព្រះ គឺជាពាក្យអាជ្ញា ដែលព្រះជាម្ចាស់តែងតាំងសាវ័កប៉ុល មិនមែនដោយចិត្តសាវ័កប៉ុលចង់ធ្វើខ្លួនឯង ពោលគឺជាសាវ័កដែលព្រះជាម្ចាស់ តែងតាំងលោកតាមបំណងព្រះហឫទ័យរបស់ទ្រង់។ ដោយសារអាជ្ញាដែលសាវ័កប៉ុលទទួលបានពីព្រះជាម្ចាស់ លោកសរសេរសំបុត្រលើកទីពីរនេះ ផ្ញើទៅកាន់ពួកជំនុំនៅទីក្រុងកូរិនថូស។ ខ្ញុំយល់ថា កិច្ចការដែលយើងបម្រើព្រះអង្គសព្វថ្ងៃនេះ យើងត្រូវបម្រើព្រះដោយទទួលស្គាល់ថា យើងមានអាជ្ញាមកពីព្រះជាម្ចាស់។ តើពាក្យថា អាជ្ញាមកពីព្រះជាម្ចាស់ មានន័យដូចម្តេច? ពាក្យនេះមានន័យថា អ្នកផ្សព្វផ្សាយព្រះបន្ទូលរបស់ព្រះជាម្ចាស់ ត្រូវមានការទ្រាំកដក្នុងចិត្តថា សេចក្តីពិតដែលកំពុងតែនិយាយ គឺជាអាជ្ញាដែលព្រះជាម្ចាស់អោយគេនិយាយ។ អាជ្ញារបស់ព្រះជាម្ចាស់ ត្រូវសម្តែងអោយឃើញថា ព្រះបន្ទូលរបស់ព្រះជាម្ចាស់ បានកែប្រែគំនិតមារយាទរបស់អ្នកនិយាយរួចជាស្រេច ទើបអាចនិយាយទ្រាប់គេបាន។ ឧទាហរណ៍ បើអ្នកផ្សព្វផ្សាយដំណឹងល្អ និយាយថា ព្រះជាម្ចាស់រំដោះគេអោយរួចពីអំពើបាបជក់ចាវី ខ្លួនគេត្រូវឈប់ជក់ចាវីមុនសិន។ ឧទាហរណ៍មួយទៀត បើនិយាយថា ព្រះជាម្ចាស់មិនពេញព្រះហឫទ័យជាមួយនឹងអ្នកណា ដែលមានកិរិយាលោភលន់ អ្នកផ្សព្វផ្សាយព្រះបន្ទូលព្រះអង្គ ត្រូវមិនប្រព្រឹត្តកិរិយាលោភលន់ជាមុនសិន។ បើអ្នកផ្សព្វផ្សាយព្រះបន្ទូលរបស់ព្រះជាម្ចាស់ មិនទាន់មានឥទ្ធិពលស្ថិតនៅក្រោមអាជ្ញា ឬចេស្តារបស់ព្រះបន្ទូលរបស់ព្រះអង្គទេ អ្នកនោះមិនបាននិយាយដោយអំណាចដែលមកពីព្រះ

ជាម្ចាស់ឡើយ ពោលគឺនិយាយតាមតែចិត្តខ្លួនឯង។ បើលោកអ្នកនិយាយព្រះបន្ទូលតាមតែចិត្តខ្លួនឯង សូមទៅលក់ចេកអាំងវិញល្អជាង កុំមកអធិប្បាយព្រះបន្ទូលអោយលំអក់ពណ៌ធ្វើអី។ សព្វថ្ងៃយើងឃើញអ្នកជឿព្រះអង្គច្រើនណាស់ មិនទាន់ដឹងខ្លួនច្បាស់លាស់ថា ព្រះបន្ទូលរបស់ព្រះជាម្ចាស់មានអាជ្ញានៅក្នុងចិត្តរបស់ខ្លួន។ ដោយសារមូលហេតុនោះ បានជាពួកជំនុំសព្វថ្ងៃនេះ មានសេចក្តីទន់ខ្សោយយ៉ាងខ្លាំង។

ពួកជំនុំសម័យដើម ទទួលការគាបសង្កត់យ៉ាងខ្លាំង។ ដោយសារមូលហេតុនោះ គេបានសារភាពនៅចំពោះមុខព្រះជាម្ចាស់ថា "ឱព្រះជាម្ចាស់អើយ ទ្រង់ពិតជាព្រះពិតប្រាកដមែន"។ លោកអ្នកបងប្អូនអើយ បើលោកអ្នកមិនស្គាល់ថាព្រះជាម្ចាស់ពិតជាព្រះជាម្ចាស់ពិតប្រាកដទេ លោកអ្នកមិនទាន់ដឹងក្តីអោយបានពិតប្រាកដនៅក្នុងខ្លួននៅឡើយទេ។ ពួកជំនុំសម័យដើម ស្គាល់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ថា ជាអំណាចរបស់ព្រះអង្គ។ ដូច្នេះហើយបានជាគេនាំគ្នាសម្រាកព្រលឹងរបស់គេនៅលើព្រះបន្ទូល។ សាវ័កប៉ុលសរសេរសំបុត្រលើកទីពីរ ទៅកាន់ទីក្រុងកូរិនថូសដោយប្រើអាជ្ញាមកពីព្រះជាម្ចាស់។

សាវ័កប៉ុលបញ្ជាក់ថា សំបុត្រដែលលោកសរសេរនេះ គឺ "លោកសរសេរតាមបំណងព្រះហឫទ័យព្រះ"។ បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ គឺជាអំណាចដែលសាវ័កប៉ុលនិយាយទៅកាន់ពួកជំនុំនៅទីក្រុងកូរិនថូស។ បើជីវិតរបស់លោកអ្នកស្ថិតនៅចំចំណុចបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ហើយ លោកអ្នកមិនចាំបាច់សួរអ្វីដល់ព្រះជាម្ចាស់ទៀតទេ។ ជីវិតរបស់លោកអ្នក មិនថាទីណាដែលលោកអ្នកមាន

បទពិសោធន៍ណាមួយដែលលោកអ្នកកំពុងឆ្លងកាត់ ឬស្ថានភាពយ៉ាងណា ដែលលោកអ្នកកំពុងទ្រាំទ្រទេ លោកអ្នកយល់ថា ហេតុការណ៍នេះ កើតឡើងដល់លោកអ្នកពីព្រោះជាបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។ ទោះបីលោកអ្នកកំពុងឈឺ សម្រាកនៅលើកន្ទេលក៏ដោយ បើលោកអ្នកយល់ថាជាបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ លោកអ្នកពេញចិត្តនឹងរឿងនោះ។

បំណងព្រះទ័យរបស់ព្រះជាម្ចាស់ គឺជាអំណាចរបស់ព្រះបន្ទូលនៃព្រះជាម្ចាស់ចំពោះជីវិតរបស់យើង។ កាលណាយើងប្រគល់ឆន្ទៈរបស់យើង អោយស្ថិតនៅក្រោមអំណាចនៃព្រះបន្ទូលរបស់ទ្រង់ នោះហើយ ជាព្រះទ័យបំណងរបស់ព្រះជាម្ចាស់ចំពោះលោកអ្នកផ្ទាល់។

"...នឹងធីម៉ូថេជាពួកបងប្អូន..."។ ខ្ញុំស្រឡាញ់ពាក្យដែលសាវ៉កប៉ុលប្រើចំពោះលោកធីម៉ូថេណាស់។ លោកធីម៉ូថេ គឺជាគូកនបម្រើព្រះជាម្ចាស់ជាមួយនឹងសាវ៉កប៉ុល នៅទីក្រុងកូរិនថូស។ នៅកន្លែងខ្លះទៀត សាវ៉កប៉ុលបានហៅធីម៉ូថេថាជាកូនក្នុងជំនឿ។ ប៉ុន្តែនៅពេលដែលសាវ៉កប៉ុលសរសេរទៅកាន់ពួកជំនុំ លោកបានហៅលោកធីម៉ូថេថា ជាគូកនបម្រើព្រះអង្គជាមួយនឹងលោក។ សាវ៉កប៉ុលមិនផាត់សំបកក្មេងជំនាន់ក្រោយទេ គឺលោកលើកមុខលើកមាត់គេអោយមានថានៈស្មើនឹងលោកដែរ។ ដូច្នេះ ទោះបីលោកធីម៉ូថេមានវ័យក្មេងក៏ដោយ សាវ៉កប៉ុលរាប់ថា ជាគូកនបម្រើព្រះអង្គជាមួយនឹងលោកផ្ទាល់។

"...ធ្វើមកពួកជំនុំនៃព្រះ..." ពួកជំនុំនៃព្រះ គឺជាពួកជំនុំដែលយើងកំពុង

និយាយនៅក្នុងមេរៀនដែលយើងសិក្សាថ្ងៃនេះ។ ទាក់ទងនឹងរឿងពួកជំនុំនៃព្រះ យើងជាគ្រីស្ទបរិស័ទ ច្រើននិយាយថា វិហារខ្ញុំ វិហារអ្នកនេះ ឬវិហារគ្រូឈ្មោះនោះ។ គ្រីស្ទបរិស័ទសព្វថ្ងៃ ចាត់ទុកថា ក្រុមជំនុំដែលខ្លួនបើសយកចូលជាសមាជិក ថាជាក្រុមជំនុំរបស់ខ្លួនផ្ទាល់។ រឿងនោះមិនមែនយ៉ាងដូច្នោះទេ។ ក្រុមជំនុំជារបស់ព្រះជាម្ចាស់។ ព្រះអម្ចាស់យេស៊ូវ បានទិញពួកជំនុំ ដោយប្រើព្រះលោហិតរបស់ព្រះអង្គ។ ដោយសារព្រះលោកហិតរបស់ទ្រង់ ដែលទ្រង់យកមកប្រើធ្វើជាតម្លៃដើម្បីទិញក្រុមជំនុំរបស់ទ្រង់ លោកអ្នកហើយនិងរូបខ្ញុំ មិនត្រូវធ្វើជាគ្រីស្ទបរិស័ទថោកទាបទេ។ យើងមិនគួរបន្ទោកក្រុមជំនុំរបស់ព្រះ ដោយចាត់ទុកថាជាក្រុមជំនុំរបស់យើងផ្ទាល់ដែរ។ សូមកុំភ្លេចថា ក្រុមជំនុំ គឺជាក្រុមជំនុំរបស់ព្រះជាម្ចាស់។

"...ដែលនៅក្រុងកូរិនថូស ព្រមទាំងពួកបរិសុទ្ធទាំងអស់គ្នា ដែលនៅគ្រប់ក្នុងស្រុកអាខៃ"។ សាវ័កប៉ុលសរសេរសំបុត្រលើកទីពីរ ទៅកាន់ពួកជំនុំនៅទីក្រុងកូរិនថូសមែន តែលោកមិនមែនចោះយកតែក្រុងកូរិនថូសមកនិយាយប៉ុណ្ណោះទេ គឺលោកសរសេរសំបុត្រនេះទៅកាន់ពួកជំនុំទាំងអស់នៅក្នុងស្រុកអាខៃ។ លោកបានផ្សព្វផ្សាយដំណឹងល្អនៅក្នុងស្រុកនោះយ៉ាងជោគជាំ។ លោកសង្ឃឹមថា ពួកជំនុំនៅទីក្រុងកូរិនថូស នឹងយកសំបុត្ររបស់លោក ដើម្បីទៅលើកទឹកចិត្តដល់ពួកជំនុំ និងមនុស្សលោកដែលរស់នៅក្នុងស្រុកអាខៃទាំងមូល។ ស្រុកអាខៃ ជាស្រុកដែលមានជីជាតិខ្លាំងណាស់។ នៅទីនោះចំការទំពាំងបាយជូរដុះល្អ និងបង្កើតផលបានច្រើនជាងកន្លែងណាៗទាំងអស់នៅក្នុងលោក។ ចំណែកសូនផ្តាវិញ សូម្បីផ្តាព្រៃក៏មានសម្ផស្សល្អណាស់

ដែរ។ នៅពេលយើងអានសំបុត្ររបស់សាវ៉កប៉ុលលើកទីពីរ យើងអាចធ្វើរូបចារម្មណ៍ អំពីដំណើរដែលអ្នកស្រុកកូរិនថូសបានឆ្លងកាត់។ ពួកអ្នកស្រុកកូរិនថូសរស់នៅក្នុងអំពើបាបយ៉ាងក្រាស់។ លុះគេបានឮដំណឹងល្អរបស់ព្រះអម្ចាស់យេស៊ូវ ភាពងងឹងក៏បានកន្លងផុតពីភ្នែករបស់គេ ពន្លឺរបស់ព្រះជាម្ចាស់បានចូលទៅក្នុងព្រលឹងរបស់គេ។ គេផ្ទេរអំពើបាបរបស់គេថ្វាយដល់ព្រះអម្ចាស់យេស៊ូវជាព្រះដ៏រស់ រួចហើយគេនាំគ្នាធ្វើដំណើរទៅគ្រប់ទីកន្លែង ដើម្បីផ្សាយដំណឹងល្អពីព្រះអម្ចាស់យេស៊ូវនៅស្រុកអាខៃ។ មនុស្សច្រើនណាស់បានជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ត។ បើតាមសាវ៉កប៉ុល លោកមានប្រសាសន៍ថា មានពួកបរិសុទ្ធជាច្រើននៅទីក្រុងអាខៃ។ ដូច្នេះ នៅក្រុងអាខៃ មានមនុស្សជឿព្រះអង្គច្រើនណាស់។

សាវ៉កប៉ុលបានសរសេរសំបុត្រទៅទីក្រុងកូរិនថូសមែន។ ពួកជំនុំនៅទីក្រុងនោះ ជាពួកជំនុំនៃព្រះ។ ពួកជំនុំដែលនៅក្នុងទីក្រុងរបស់លោកអ្នក ពួកជំនុំដែលនៅក្បែរផ្ទះលោកអ្នក គឺជាពួកជំនុំរបស់ព្រះជាម្ចាស់។ សូមកុំភ្លេចរឿងនេះអោយសោះ។

សូមឱ្យអ្នករាល់គ្នាបានប្រកបដោយព្រះគុណ នឹងសេចក្តីសុខ សាន្តមកអំពីព្រះដ៏ជាព្រះវរបិតានៃយើង ហើយអំពីព្រះអម្ចាស់យេស៊ូវគ្រីស្ត (២កូរិនថូស១:២)។

សាវ៉កប៉ុលតែងតែប្រើការជម្រាបសួរជានិច្ច ពេលលោកសរសេរទៅកាន់

ពួកជំនុំរបស់ព្រះជាម្ចាស់នៅតាមទីកន្លែងនានា។ ឯការជម្រាបសួរបស់លោក លោកតែងជូនពរដល់គេ អោយគេបានប្រកបដោយព្រះគុណ និងសេចក្តីសុខសាន្តមកពីព្រះដ៏ជាព្រះវរបិតា និងពីព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ ព្រះគុណ និងសេចក្តីសុខសាន្ត គឺជាអំណោយទាន ដែលព្រះជាម្ចាស់ប្រទានមកដល់ពួកអ្នកជឿគ្រប់រូប។

សេចក្តីសុខសាន្តដែលព្រះជាម្ចាស់
ប្រទានមកសម្រាប់ជីវិតមនុស្សលោក

សូមសរសើរដល់ព្រះ ដ៏ជាព្រះវរបិតានៃព្រះយេស៊ូវគ្រីស្ទ ជាអម្ចាស់នៃយើងរាល់គ្នា គឺជាព្រះវរបិតាដ៏មានសេចក្តីមេត្តាករុណា ជាព្រះដ៏កំសាន្តចិត្តគ្រប់ជំពូក (២កូរិនថូស១:៣)។

សាវ័កប៉ុល ចូលចិត្តសរសើរដល់ព្រះដ៏ជាព្រះវរបិតានៃព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ អ្នកណាដែលសរសើរដល់ព្រះជាម្ចាស់ អ្នកនោះទទួលស្គាល់ពីសិរីល្អរបស់ព្រះជាម្ចាស់ ដែលបានសម្តែងមកខ្លួនលោកផ្ទាល់ ក៏ដូចជាមកលើពិភពលោកទាំងមូលដែរ។ យើងគ្រប់គ្នាដែលជាកូនរបស់ព្រះជាម្ចាស់ ត្រូវចេះសរសើរតម្កើងដល់ព្រះជាម្ចាស់រៀងរាល់ថ្ងៃនៅក្នុងជីវិតរបស់យើង។ ការសរសើរដល់ព្រះជាម្ចាស់ ជាបុគ្គលិកលក្ខណៈ ដោយឡែកមួយរបស់ពួកគ្រីស្ទបរិស័ទ។ បើគ្រីស្ទបរិស័ទមិនចេះសរសើរដល់

ព្រះទេ ក៏វិយាប្រព្រឹត្តរបស់ខ្លួន បញ្ជាក់ថា ខ្លួនមិនមែនជាកូនរបស់ព្រះអង្គឡើយ។ ព្រះជាម្ចាស់ពេញព្រះហឫទ័យ និងក៏វិយាប្រព្រឹត្តដែលមនុស្សលោកសរសើរដល់ព្រះនាមទ្រង់។

ស្តេចដាវីឌចូលចិត្តសរសើរព្រះជាម្ចាស់ណាស់។ ក្សត្រអង្គនេះ មានបន្ទូលនៅក្នុងគម្ពីរទំនុកដំកើង៣៤:១ថា "ខ្ញុំនឹងលើកសរសើរដល់ព្រះយេហូវ៉ា គ្រប់ពេលវេលាសេចក្តីសរសើរពីទ្រង់នឹងនៅក្នុងមាត់ខ្ញុំជានិច្ច"។ គ្រីស្ទបរិស័ទណា ដែលចូលចិត្តរអ៊ូរទាំគ្រីស្ទបរិស័ទនោះ មិនចេះសរសើរដល់ព្រះជាម្ចាស់ទេ។ យើងជាគ្រីស្ទបរិស័ទ គួរចេះសរសើរដល់ព្រះនាមព្រះអម្ចាស់។ គម្ពីរទំនុកដំកើង៥០:២៣ សម្តែងថា "អ្នកណាដែលថ្វាយដង្វាយជាសេចក្តីអរព្រះគុណ នោះក៏លើកដំកើងអញដែរ ហើយអញនឹងសំដែងសេចក្តីសង្គ្រោះរបស់ព្រះ ដល់អ្នកណាដែលរៀបផ្លូវរបស់ខ្លួនឱ្យត្រង់"។

"សូមសរសើរដល់ព្រះដ៏ជាព្រះវរបិតានៃព្រះយេស៊ូវគ្រីស្ទ..." ព្រះជាម្ចាស់ជាព្រះវរបិតា។ ក្នុងនាមទ្រង់ជាព្រះវរបិតា ទ្រង់ទទួលនាទីសំខាន់ក្នុងសំណុំតួអង្គព្រះត្រៃឯក។ ព្រះវរបិតាស្រឡាញ់ដល់មនុស្សលោកខ្លាំងណាស់ ចានជាទ្រង់ប្រទានព្រះរាជបុត្រារបស់ទ្រង់តែមួយ គឺព្រះនាមព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ ក្នុងនាមព្រះយេស៊ូវគ្រីស្ទជាព្រះរាជបុត្រា មិនមានន័យថា ទ្រង់ចាប់កំណើតមកជាព្រះទេ ពោលគឺព្រះអង្គបំពេញតួនាទីមួយក្នុងសំណុំតួអង្គព្រះត្រៃឯក ជាមួយនឹងព្រះវរបិតា។ នៅក្នុងសំណុំតួអង្គព្រះត្រៃឯក មានអង្គព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ។ ព្រះអម្ចាស់យេស៊ូវបំពេញតួនាទីជាព្រះរាជបុត្រាដែលមានព្រះជន្មអស់កល្បជានិច្ច។ ចំណែកឯព្រះវរបិតា

វិញ ទ្រង់គង់នៅតាំងពីអស់កល្បរហូតដល់អស់កល្ប។ លោកអ្នកឃើញព្រះជាម្ចាស់ ជាព្រះវរបិតា និងព្រះយេស៊ូវជាព្រះរាជបុត្រា។ អង្គទាំងពីរនេះ ស្ថិតស្ថេរនៅអស់កល្បជានិច្ច តាំងពីអតីតកាល បច្ចុប្បន្នកាល និងអនាគតកាល។ ព្រះវរបិតាមិនបានបង្កើតព្រះយេស៊ូវគ្រីស្ទទេ ឯព្រះយេស៊ូវគ្រីស្ទ ក៏មិនបានកើតចេញព្រះវរបិតាក្នុងនាមទ្រង់ជាព្រះរាជបុត្រាដែរ។ បើតាមតូនាទី អង្គទាំងពីរនេះ ព្រះវរបិតា និងព្រះរាជបុត្រា នៅក្នុងសំណុំព្រះត្រៃឯក ទ្រង់គង់នៅតាំងពីអស់កល្ប និងដល់អស់កល្បតរៀងទៅ។ នៅក្នុងខនេះ សាវ៉កប៉ុលបញ្ជាក់បន្ថែមទៀតថា "...គឺជាព្រះវរបិតា ដ៏មានសេចក្តីមេត្តាករុណា ជាព្រះដ៏កំសាន្តចិត្តគ្រប់ជំពូក"។ មុននឹងយើងសិក្សាមេរៀននេះជាបន្តទៅទៀត ខ្ញុំចង់ពន្យល់ពាក្យបីម៉ាត់ ដែលតែងតែមាននិយាយនៅក្នុងព្រះគម្ពីរជានិច្ច។ ពាក្យទាំងបីនោះ ជាអំបោះត្បាញក្រមា ក្នុងកីតែមួយ។ ពាក្យទាំងបីនោះ គឺស្រឡាញ់ មេត្តាករុណា និងព្រះគុណ។

សព្វថ្ងៃយើងឲ្យគេនិយាយពាក្យមួយ ដែលគេប្រើជាច្រើនលើក ច្រើនសារ ច្រើនកាល:ទេស:គ្រប់កន្លែងទាំងអស់។ ពាក្យនោះ គឺពាក្យស្រឡាញ់។ ពាក្យនេះ មានខ្លឹមសារ ពីព្រោះបើគ្មានសេចក្តីស្រឡាញ់ទេ ជីវិតរបស់មនុស្សលោក គ្មានន័យទាល់តែសោះ។ ប៉ុន្តែព្រះជាម្ចាស់មិនបានសង្គ្រោះយើងអោយរួចពីបាប ដោយសារសេចក្តីស្រឡាញ់របស់ទ្រង់ឡើយ។ មែនហើយ ទ្រង់ស្រឡាញ់ដល់យើង ទ្រង់ស្រឡាញ់ដល់យើងខ្លាំងណាស់។ យើងមិនអាចយល់បាន ពីជំរៅ នៃសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ចំពោះរូបយើងបានទេ។ បើយើងអាចយល់ពីសេចក្តីស្រឡាញ់របស់ព្រះបាន

ទើបយើងយើញ ទឹកចិត្តដ៏ធំធេងរបស់ព្រះជាម្ចាស់ ចំពោះយើងគ្រប់គ្នា។ ប៉ុន្តែ ទោះជាព្រះអង្គស្រឡាញ់ដល់យើងយ៉ាងណាក៏ដោយ ព្រះអង្គមិនអាចសង្គ្រោះរូបយើង អោយរួចពីបាបដោយសារសេចក្តីស្រឡាញ់របស់ទ្រង់ទេ។ ព្រះបន្ទូលរបស់ព្រះអង្គ សម្តែងថា ទ្រង់សង្គ្រោះរូបយើងអោយរួចពីបាប ដោយសារព្រះគុណរបស់ទ្រង់។

ចុះអ្វីទៅដែលហៅថា ជាព្រះគុណ? ព្រះគុណ គឺជាអំពើល្អដែលយើងទទួលបានដោយមិនសមនឹងទទួលបានឡើយ។ ចំណុចនេះមានន័យថា យើងទទួលរួចពីបាបមិនមែនដោយសារគុណស្រ័យដែលព្រះជាម្ចាស់ជំពាក់យើងទេ។ ព្រះជាម្ចាស់ស្រឡាញ់ដល់យើង តែព្រះអង្គសង្គ្រោះរូបយើងអោយរួចពីបាបមិនមែនដោយសារសេចក្តីស្រឡាញ់ឡើយ។ ទ្រង់សង្គ្រោះយើងអោយរួចពីបាបដោយសារព្រះគុណ។ ដោយហេតុអ្វី? ពីព្រោះសាវ័កប៉ុលបញ្ជាក់ច្រាប់យើងថា ព្រះជាម្ចាស់ ទ្រង់ជាព្រះដ៏មានសេចក្តីមេត្តាករុណា។ ទ្រង់ជាព្រះវរបិតាដ៏មានសេចក្តីមេត្តាករុណា។ ដោយសារសេចក្តីមេត្តាករុណារបស់ទ្រង់ ទ្រង់ប្រទានសេចក្តីមេត្តាករុណារបស់ទ្រង់តែមួយ ដើម្បីអោយមកសុគតធ្វើជាអង្គសង្គ្រោះរបស់យើង។ ដើម្បីសង្គ្រោះមនុស្សលោកអោយរួចពីបាប ទ្រង់មិនប្រទានមធ្យោបាយណា ផ្លូវណា ឬវិធីណាផ្សេងក្រៅពីផ្តល់ព្រះរាជបុត្រារបស់ទ្រង់ អោយមកសុគតជំនួសអំពើបាបយើងឡើយ។ ទឹកចិត្តដែលព្រះអង្គប្រទានព្រះរាជបុត្រាតែមួយរបស់ទ្រង់ អោយមកសុគតជំនួសយើង នោះហើយដែលហៅថា ជាព្រះគុណដែលមកពីព្រះវរបិតា។ ទ្រង់ជាព្រះវរបិតាដ៏មានសេចក្តីមេត្តាករុណា។ សេចក្តីមេត្តាករុណារបស់ព្រះជាម្ចាស់ឥតមានកំរិតឡើយ។ ដូច្នេះបានជាសាវ័កប៉ុលចង់អោយយើង

គ្រប់គ្នាបានប្រកបដោយព្រះគុណ ពោលគឺអោយព្រះគុណរបស់ព្រះជាម្ចាស់មានរឹតតែច្រើនឡើងនៅក្នុងជីវិតរបស់យើង។

តើលោកអ្នកត្រូវការព្រះគុណរបស់ព្រះជាម្ចាស់នៅថ្ងៃនេះដែរឬទេ? បើលោកអ្នកត្រូវការប្រាក់ លោកអ្នកចាំបាច់ត្រូវធ្វើដំណើរទៅកន្លែងដែលគេអោយខ្ចីប្រាក់។ ប៉ុន្តែ បើលោកអ្នកត្រូវការព្រះគុណរបស់ព្រះជាម្ចាស់វិញ លោកអ្នកចាំបាច់ចូលទៅព្រះវរបិតាដ៏មានសេចក្តីមេត្តាករុណា។ ព្រះវរបិតាដែលទ្រង់មានសេចក្តីមេត្តាករុណា ទ្រង់អាចជួយដល់លោកអ្នក បើលោកអ្នកសម្រេចចិត្តទៅឯព្រះអង្គ។ តាមពិតអ្វីៗទាំងអស់ ដែលយើងមានសព្វថ្ងៃនេះ គឺដោយសារព្រះគុណរបស់ព្រះជាម្ចាស់ដែលផ្តល់មកដល់ជីវិតយើងតែប៉ុណ្ណោះ។ យើងមិនសមនឹងទទួលអ្វីដែលយើងមានសព្វថ្ងៃនេះទេ។ ខ្ញុំផ្ទាល់មិនសមនឹងទទួលនាទី និងរបស់របរដែលខ្ញុំមានសព្វថ្ងៃនេះដែរ។ ខ្ញុំមិនមែនជាអ្នកមានទេ អ្វីៗដែលខ្ញុំមានសព្វថ្ងៃនេះ គឺជាព្រះគុណរបស់ព្រះជាម្ចាស់សម្រាប់ជីវិតខ្ញុំហើយ។

ម្យ៉ាងវិញទៀតខ្ញុំអាចបម្រើដល់ព្រះជាម្ចាស់សព្វថ្ងៃនេះបាន ដោយសារព្រះគុណរបស់ទ្រង់។ លោកអ្នកមិនអាចស្គាល់ខ្លួនខ្ញុំ ដូចខ្ញុំស្គាល់ខ្លួនឯងទេ។ លោកអ្នកប្រហែលជាមិនចង់ស្តាប់សម្តីដែលខ្ញុំកំពុងតែនិយាយនេះទេ។ ប៉ុន្តែ សូមកុំទាន់អាលច្រានខ្ញុំចោលធ្វើអ្វី។ បើខ្ញុំស្គាល់លោកអ្នក ដូចលោកអ្នកស្គាល់ខ្លួនឯង ខ្ញុំមិនរវល់ជ្រលក់មាត់ជាមួយនឹងលោកអ្នកដែរ។ លោកអ្នក ហើយនិងរូបខ្ញុំផ្ទាល់ ត្រូវការព្រះគុណរបស់ព្រះជាម្ចាស់គ្របដណ្តប់មកលើយើងរៀងរាល់ថ្ងៃ។ ខ្ញុំអាចបម្រើដល់ព្រះជាម្ចាស់

បាន ដូចខ្ញុំកំពុងបម្រើព្រះអង្គសព្វថ្ងៃនេះ ដោយសារព្រះគុណរបស់ព្រះជាម្ចាស់តែម្យ៉ាងប៉ុណ្ណោះ។

ឥឡូវនេះ សូមយើងនិយាយពីកិច្ចអនុវត្តជាក់ស្តែងនៅក្នុងជីវិតយើងម្តង។ ជំពោះរូបខ្ញុំផ្ទាល់ ខ្ញុំត្រូវនិយាយសេចក្តីដែលខ្ញុំមិនចូលចិត្តនិយាយ ដូចខ្ញុំហៀបនឹងនិយាយនេះ។ នៅក្នុងជីវិតខ្ញុំ មានបទពិសោធន៍ជូរចត់ជាច្រើន។ ខ្ញុំចង់អោយបទពិសោធន៍ជូរចត់ទាំងនោះ កន្ងងផុតពីខ្ញុំទៅ។ ប៉ុន្តែសេចក្តីជូរចត់ទាំងអម្បាលមាណនោះ កើតឡើងដល់ខ្ញុំដោយសារព្រះគុណរបស់ព្រះជាម្ចាស់។ ខ្ញុំស្អប់ពាក្យនេះណាស់ តែរឿងនោះជារឿងពិត។ អ្វីៗទាំងអស់ដែលយើងមានសព្វថ្ងៃនេះ គឺដោយសារព្រះគុណរបស់ព្រះជាម្ចាស់។ ព្រះអង្គជាព្រះវរបិតាដ៏មានសេចក្តីមេត្តាករុណា។

សាវ៉កប៉ុល មិនគ្រាន់តែហៅព្រះវរបិតាថាជាព្រះដ៏មានសេចក្តីមេត្តាករុណាប៉ុណ្ណោះទេ ទ្រង់ជាព្រះដ៏កំសាន្តចិត្តគ្រប់ជំពូកថែមទៀតផង។ ពាក្យថា កំសាន្តចិត្ត មានន័យថា ទោះបីស្ថានភាពជីវិតឆ្លងកាត់រឿងរ៉ាវ ការលំបាក ឬសេចក្តីអរសប្បាយយ៉ាងណាក្តី ការកំសាន្តចិត្តពីព្រះជាម្ចាស់ នៅជាមួយយើងជានិច្ច។ ធ្វើដូចម្តេច ដើម្បីអោយដឹងថា សេចក្តីកំសាន្តចិត្តរបស់ព្រះជាម្ចាស់ គ្របដណ្តប់មកលើជីវិតយើង? រឿងនេះអាចកើតឡើងទៅបាន ដោយសារជីវិតត្រូវឆ្លងកាត់ទុក្ខលំបាក។ ទុក្ខលំបាក ដែលកើតមានដល់ជីវិតយើងគ្រប់រូប ប្រៀងឧបមាដូចជាទឹកអាស៊ីត ដែលគេជះមកលើរូបយើងផ្ទាល់។ កំពុងតែយើងជួបប្រទះជាមួយនឹងទុក្ខលំបាក យើងឃើញសេចក្តីកំសាន្តចិត្តរបស់ព្រះជាម្ចាស់ គ្របដណ្តាប់មកលើរូបយើងផ្ទាល់។ ពេលលោកអ្នកមានជម្ងឺ សេចក្តី

កំសាន្តចិត្តរបស់ព្រះជាម្ចាស់គ្របដណ្តប់ដល់លោកអ្នក។ នៅពេលមាននរណាម្នាក់ស្លាប់នៅក្នុងគ្រួសាររបស់លោកអ្នក សេចក្តីកំសាន្តចិត្តរបស់ព្រះជាម្ចាស់ គ្រប់ដណ្តប់មកលើចិត្តរបស់លោកអ្នក។ ទ្រង់ជាព្រះ ដែលកំសាន្តចិត្តយើង នៅគ្រប់ជំពូកទាំងអស់។

ពេលយើងប្រឈមមុខជាមួយនឹងទុក្ខលំបាក យើងអាចជ្រើសរើសការពីរយ៉ាង។ ទីមួយ យើងអនុញ្ញាតអោយសេចក្តីកំសាន្តចិត្តរបស់ព្រះជាម្ចាស់ គ្រប់ដណ្តប់មកលើជីវិតយើង។ ទីពីរ យើងអាចបះបោរទាស់ជាមួយនឹងព្រះអង្គ ដោយចោទព្រះអង្គតាមគំនិតអគតិរបស់យើង។ បើលោកអ្នកមិនសប្បាយចិត្ត ពេលលោកអ្នកជួបប្រទះនឹងទុក្ខលំបាក សូមទូលថ្វាយព្រះអង្គតាមត្រង់ទៅចុះ។ ព្រះអង្គជ្រាបពីទីកចិត្តរបស់លោកអ្នកហើយ។ លោកអ្នកចាំបាច់ត្រូវទូលថ្វាយដល់ព្រះអង្គ គ្រប់រឿងទាំងអស់ ទោះសុខឬទុក្ខក្នុងជីវិតក្តី ដ្បិតទ្រង់ជាព្រះដែលជួយកំសាន្តចិត្ត។

ពាក្យថា "កំសាន្តចិត្ត" ក្នុងភាសាក្រេកហៅថា ចាំរ៉ាក្លេអូ ប្រែថា អមដំណើរ។ ព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះអង្គ ធ្វើដំណើរអមជាមួយនឹងយើងរៀងរាល់ថ្ងៃ។ គម្ពីរយ៉ូហាន១៤:១៨សម្តែងថា "ខ្ញុំមិនចោលអ្នករាល់គ្នាឱ្យនៅកំព្រាទេ ខ្ញុំនឹងមកឯអ្នករាល់គ្នាវិញ"។ ព្រះអង្គមិនចង់អោយយើងនៅជាកូនកំព្រាទេ ពោលគឺព្រះអង្គចង់អមដំណើរយើងក្នុងការធ្វើដំណើរឆ្លងកាត់ពិភពលោកសព្វថ្ងៃនេះ។ គម្ពីរយ៉ូហាន១៦:៧សម្តែងថា "ខ្ញុំប្រាប់តាមត្រង់ថា ដែលខ្ញុំទៅ នោះមានប្រយោជន៍ដល់អ្នករាល់គ្នាវិញ ដ្បិតបើខ្ញុំមិនទៅទេ នោះព្រះដ៏ជាជំនួយក៏មិនមកឯអ្នករាល់គ្នាដែរ តែបើខ្ញុំទៅ នោះខ្ញុំ

នឹងចាត់ទ្រង់ឱ្យមក"។ ព្រះជាម្ចាស់ពិតជាព្រះវរបិតាដ៏ជួយកំសាន្តចិត្តយើងគ្រប់ជំពូក។

យើងស្លេះការសិក្សាគម្ពីរ២កូរិនថូសត្រឹមណេះសិនចុះ។ ទំរាំយើងជួបគ្នាលើកក្រោយ សូមព្រះជាម្ចាស់ប្រទានពរដ៏ធំឧត្តម ដល់លោកអ្នកបងប្អូនគ្រប់ៗគ្នា។ "ដើរជាមួយនឹងព្រះ ពិតជាប្រទះនឹងព្រះយេស៊ូវជាមិនខាន!"